## III) ទីភ្នាក់ងារនីតិប្រតិបត្តិ និងដំណើរការរដ្ឋបាលៈ

### ១) សមត្ថកិច្ចមិនច្បាស់លាស់ ឬត្រួតគ្នារបស់ស្ថាប័នផ្សេងៗ

នៅក្នុងផ្នែកនៃពង្រាងច្បាប់ ដែលនិយាយអំពីសមត្ថកិច្ចរបស់អាជ្ញាធរដែលភារកិច្ចជាអ្នកអនុវត្តច្បាប់ អាចមានបញ្ហាមួយចំនួនកើតឡើងៈ

បញ្ហាមួយនៃបញ្ហាទាំងនេះគឺថា អត្ថបទច្បាប់ អាចបណ្តាលឱ្យការទទួលខុសត្រូវ និងសមត្ថកិច្ចមិនច្បាស់លាស់ ឬជាន់គ្នានៃស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល ។ ហេតុផល អាចបណ្តាលមកពីអ្នកធ្វើច្បាប់ពុំបានកត់សំគាល់នូវសមត្ថកិច្ចរបស់ស្ថាប័នដែលមានស្រាប់ ។ ហេតុផលមួយទៀត អាចបណ្តាលមកពីអ្នកធ្វើច្បាប់ចង់ជៀសវាងការចូលដៃជើងនៅទំនាស់ដែលកំពុងកើតមានរវាងស្ថាប័នពីរ ។

<u>ឧទាហរណ៍ៈ</u>

- ពង្រាងច្បាប់ស្តីពីជលផល អនុញ្ញាតឱ្យរដ្ឋបាលនេសាទផ្តល់លិខិតកាន់កាប់ដល់ដែននេសាទ ប៉ុន្តែការធ្វើដូចនេះអាចមានទំនាស់ជាមួយអាជ្ញាធរនៃក្រសួងគ្រប់គ្រងដីធ្លី ក្នុងការចេញលិខិតកាន់កាន់អចលនទ្រព្យ ។
- មាត្រា៩ និង១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ កំណត់នូវសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ <u>និង</u>ក្រសួងការពារជាតិ ទៅលើកម្មវត្ថុតែមួយ (ការចុះបញ្ជីអាវុធ ឬបទបញ្ជានៃការជន្លៀស) ដោយពុំមានការបែងចែកច្បាស់លាស់ ឬ វិធានជាអាទិភាព សំរាប់ករណីដែលក្រសួងទាំងពីរនេះអនុវត្តសមត្ថកិច្ចរបស់ខ្លួន នៅពេលជាមួយគ្នា ឬនៅពេលមានទំនាស់ជាមួយសកម្មភាពរបស់ខ្លួនទៅវិញទៅមក ។

### ២) ការផ្តល់អំណាចហួសហេតុ

#### ក) អំណាចដែលមិនស្របតាមរដ្ឋធម្មនុញ្ញ និងដែលមិនចាំបាច់

បញ្ហាមួយទៀតដែលអាចកើតឡើងនោះគឺថា ពង្រាងច្បាប់នេះផ្តល់អំណាចហួសហេតុដល់អាជ្ញាធរ ។ នោះមានន័យថា ឧទាហរណ៍ ច្បាប់អនុញ្ញាតឱ្យអាជ្ញាធរធ្វើសកម្មភាពតាមមធ្យោបាយមួយដែលអាចរំលោភសិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នៃដំណើរការសមស្របមួយ ឬបញ្ញត្តិច្បាប់ព្រហ្មទណ្ឌ ។

<u>ឧទាហរណ៍ៈ</u>

ជំពូកទី១៤ នៃពង្រាងច្បាប់ស្តីពីជលផល មានបទប្បញ្ញត្តិជាច្រើនដែលហាក់ដូចជាផ្តល់អំណាចច្រើនហួសហេតុដល់មន្ត្រីរដ្ឋបាលជលផល ដោយរាប់បញ្ចូលទាំងសិទ្ធិកាន់អាវុធ រឹបអូសវត្ថុតាង ប៉ាន់ស្មានការផាកពិន័យ និងឆែកឆេរជនជាប់សង្ស័យពីបទល្មើស ។ ទោះបីជា មន្ត្រីជលផលអាចត្រូវបានគេចាត់ទុកថាជាមន្ត្រីនគរបាលយុត្តិធម៌ យោងតាមមាត្រា៣៥ ដល់ ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏អំណាចរបស់ពួកគេនៅក្នុងតួនាទីនេះត្រូវតែកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌនេះផងដែរ ហើយមិនអាចត្រូវបានពង្រីកដោយច្បាប់ជលផលឡើយ[២៦] ។

#### ខ) អំណាចតុលាការ និង/ឬ ការមិនរាប់បញ្ចូលនៃការត្រួតពិនិត្យរបស់តុលាការ

ការផ្តល់នូវអំណាចដែលជិតស្មើអំណាចតុលាការទៅឱ្យអាជ្ញាធរ ឬកាត់បន្ថយនូវការត្រួតពិនិត្យដោយតុលាការលើសកម្មភាពរបស់អាជ្ញាធរ អាចបំពានលើគោលការណ៍នៃការបែងចែកអំណាច ។

---

[២៦] សូមមើលរបាយការណ៍ Oxfam ស្តីពីដំណើរការពិគ្រោះយោបល់ស្តីពីច្បាប់ជលផល ដែលពាក់ព័ន្ធនឹងមាត្រា៨៣ និង ៨៦ ទំព័រទី ៣៧ ។

ឧទាហរណ៍:

- មាត្រា៩៣ នៃពង្រាងច្បាប់ស្តីពីជលផល ផ្តល់អំណាចតុលាការ ដើម្បីស៊ើបអង្កេត និងផាកពិន័យចំពោះបទល្មើស និងដកការចោទប្រកាន់ប្រឆាំងអ្នករំលោភ ។ មាត្រានេះ បំពានរដ្ឋធម្មនុញ្ញដែលចែងយ៉ាងច្បាស់នៅក្នុងមាត្រា១២៩ CC ចែងថា មានតែចៅក្រមប៉ុណ្ណោះដែលមានអំណាចវិនិច្ឆ័យក្តី និងរំលោភគោលការណ៍នៃការបែងចែកអំណាច ដែលមានចែងនៅក្នុងមាត្រា១៣០ CC[២៧] ។
- ការរំលាយសមាគមមួយដោយបទបញ្ជារដ្ឋបាលដ៏សាមញ្ញមួយ ដូចមានចែងនៅក្នុងមាត្រា១៦ ឃ្លាទី២ ចំនុចទី២ នៃពង្រាងច្បាប់ស្តីពី NGOs និងសមាគម សមស្របតាមរដ្ឋធម្មនុញ្ញ ពីព្រោះ មាត្រានេះចែងយ៉ាងច្បាស់អំពីសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងចំពោះបទបញ្ជានេះទៅតុលាការ ។ ដូច្នេះ ការត្រួតពិនិត្យផ្នែកតុលាការចាំបាច់នៃវិធានការបែបនេះ ត្រូវបានធានា ។

### គ) ប្រតិភូកម្មអំណាចក្នុងការធ្វើបទបញ្ជាច្រើនពេក[២៨]

លើសពីនេះទៀត ច្បាប់អាចធ្វើប្រតិភូកម្មនូវអំណាចធ្វើបទបញ្ជាច្រើនពេក ដល់ផ្នែករដ្ឋបាល ។ ពាក់ព័ន្ធនឹងគោលការណ៍នៃការបែងចែកអំណាច សេចក្តីសម្រេចសំខាន់ត្រូវតែធ្វើឡើងដោយច្បាប់ ។ អំណាចធ្វើបទបញ្ជា អាចត្រូវបានប្រគល់ទៅឱ្យអង្គនីតិប្រតិបត្តិ ដោយអង្គនីតិបញ្ញត្តិបានតែចំពោះប្រធានបទទាំងឡាយណាដែលមិនត្រូវការពិភាក្សាដោយអ្នកធ្វើច្បាប់នៅក្នុងដំណើរការនៃការធ្វើច្បាប់ពេញលេញមួយ ប៉ុន្តែ ដែលទាមទារនូវការឆ្លើយតបដ៏រហ័ស និងដែលអាចបត់បែនបានមួយរបស់អង្គនីតិប្រតិបត្តិ ឬដែលមានលក្ខណៈលំអិតពេកដែលច្បាប់ពុំអាចកំណត់នូវសេចក្តីលំអិតផ្នែកបច្ចេកទេសតូចៗទាំងអស់បាន ។

នៅក្នុងករណីណាក៏ដោយ រដ្ឋធម្មនុញ្ញ គួរតែត្រូវបានពិនិត្យជាមុនសិនថា តើវាទាមទារនូវបទប្បញ្ញត្តិដោយ"ច្បាប់"មួយ (ដូចជា នៅក្នុងមាត្រា៤១ II CC: "របបសារពត៌មានត្រូវកំណត់ដោយច្បាប់") នៅក្នុងករណីនេះ ការកំណត់ណាមួយដោយអនុក្រឹត្យនោះ មិនគ្រប់គ្រាន់ទេ ។ ម្យ៉ាងវិញទៀត សេចក្តីសម្រេចរយៈពេលយូរ និងដែលមានទស្សនៈវែងឆ្ងាយត្រូវតែធ្វើឡើងតាមទម្រង់ច្បាប់ ។ វិធានដូចគ្នានេះអនុវត្តបានប្រសិនបើ ផលវិបាកហិរញ្ញវត្ថុធ្ងន់ធ្ងរសំរាប់ថវិកាជាតិគឺនៅតាំងមួយកន្លែង ឬប្រសិនបើនិយតកម្មនេះជ្រៀតជ្រែកជាមួយសិទ្ធិមនុស្សជាមូលដ្ឋាន ។

ឧទាហរណ៍:

- បទប្បញ្ញត្តិអំពីពណ៌ និងទំហំនៃផ្លាកលេខឡានមួយ អាចសម្រេចទៅលើអនុក្រឹត្យមួយបាន ពីព្រោះនេះគឺជាសេចក្តីលំអិតផ្នែកបច្ចេកទេសមិនសំខាន់មួយ ដែលអ្នកធ្វើច្បាប់មិនត្រូវខ្វល់ខ្វាយ ។
- ប៉ុន្តែ ដែនកំណត់នៃអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកធ្វើច្បាប់មិនត្រូវបណ្តោយឱ្យ អនុក្រិត្យរដ្ឋាភិបាលនៃក្រសួងមហាផ្ទៃ (ព្រោះវាត្រូវបានធ្វើឡើងដោយមាត្រា៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់) សម្រេចបានទេ ព្រោះចំណុចនេះអាចមើលស្រាលស្វ័យគ្រប់គ្រង និងសិទ្ធិជាមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- វាក៏ត្រូវការច្បាប់មួយផងដែរដើម្បីកំណត់ថា តើគេអាចចេញលិខិតអនុញ្ញាតកាន់កាប់អាវុធដល់ជនស៊ីវិលក្រោមលក្ខខណ្ឌអ្វីខ្លះ? ការកំណត់អំពីលក្ខខណ្ឌទាំងនេះ មិនត្រូវបណ្តោយឱ្យធ្វើឡើងតាមរយៈប្រកាសរបស់ក្រសួងមហាផ្ទៃ ដូចគេបានធ្វើនៅក្នុងមាត្រា១១ ឃ្លាទី៤ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធឡើយ ។

[២៧] សូមមើលរបាយការណ៍ Oxfam ស្តីពីដំណើរការពិគ្រោះយោបល់ស្តីពីច្បាប់ជលផល ទំព័រ ៤៣ : យោបល់របស់ COHCHR

[២៨] ចំពោះពត៌មានលំអិតស្តីពីប្រធានបទនេះ សូមមើល : ប៉ាទ្រីស្សៀ បារ (Patricia Baars) ការតាក់តែងច្បាប់ ទំព័រ ៣៨ និងមូលនិធិខនរ៉ាដ អាដេណូអឺរ សៀវភៅស្តីពីការធ្វើពង្រាងច្បាប់ និង នីតិកម្មទំព័រ ២៧-៣២ និង ៥៧ , ៥៨ ។